-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៣៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី OSANAI MIEKO ប្រធានអង្គការ JHP ជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ២៤.៩៥០ USD សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង បំពាក់ដោយសម្ភារឹមគ្រប់គ្រាន់ និង បង្គន់អនាម័យ ០១ខ្នង ជូនសាលាបឋមសិក្សា ព្រះរាជអគ្គមហេសី ភូមិស្រះកែវ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១** : ត្រូវបានតែងតាំងលោក **ឆាយ សាវុធ** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤១ សហវ

ប្រកាសអន្តរក្រសួង

ស្តីពី

ការបង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ គ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២

ឌ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០៣

-បានឃើញ អនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល

## សំរេច

ប្រការ១: បង្កើតក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ដែលមានសមាជិកដូចរាយនាមខាងក្រោម:

១. ឯកឧត្តម ជុំ គីមឡេង អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២. ឯកឧត្តម តែ គុយសៀង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល អនុប្រធាន

៣. ឯកឧត្តម ឆយ អូន អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

៤. លោក ទិន ឃន ប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥. លោក នួច ឡេង ប្រធាននាយកដ្ឋានថវិកា.និងហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦. លោក ឆាយ ទុំឆ ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៧. លោក លី សន្ធិ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨. លោក ជា គីមឡុង ប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល សមាជិក

ប្រការ២: លេខាធិការដ្ឋានរបស់ក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវបានបង្កើត និងមានសមាជិកដូចខាងក្រោម:

១. លោក ហ៊ីង សុវណ្ណ អនុប្រធានទី១រតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២. លោក យិន ថាវ អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

៣. លោកស្រី យត់ សម្បត្តិ អនុប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល អនុប្រធាន

៤. លោក អៀង ស៊ុនលី អនុប្រធានទី១នាយកដ្ឋានថវិកា.និងហិ.កិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥. លោក ឈឹម សារ៉េត អនុប្រធានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦. លោក ទន្សៃ វិជាធុល អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៧. លោក ស៊ាន ម៉ារឡូត ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៨. លោក ជា ម៉ិន ប្រធានការិយាល័យគ្រប់គ្រងការងារហិ.កិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩. កញ្ញា ឃុត ដាវទី ប្រធានការិយាល័យផែនការ ក្រសួងសុខាភិបាល សមាជិក

១០. លោក លី សំរុល ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងសុខាភិបាល សមាជិក

១១. លោក ឯក ចន្ថា ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១២. លោក ខួន លក្ខណា មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៥

ប្រការ៣: ក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ត្រូវទទួលបន្ទុកៈ

- កំណត់អោយបានអំពីមូលហេតុ ដែលនាំអោយការបើកផ្តល់សាច់ប្រាក់មានកំរិតទាបដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម ពិសេសវិស័យអប់រំ និងសុខាភិបាល ព្រមទាំងផ្តល់អនុសាសន៍ដើម្បីធ្វើសកម្មភាពកែសំរួល និងធ្វើអោយប្រសើរឡើង
- កំណត់អោយបាននូវការលំបាកនានារបស់ក្រសួងស្ថាប័ន ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព និងលើកឡើងនូវវិធានការដោះស្រាយ
- រៀបចំផែនការសកម្មភាពរយៈពេលខ្លីស្តីពីការបង្កើនសន្ទុះនៃការបើកផ្តល់សាច់ប្រាក់ ដោយផ្អែកតាមការសំរេចចិត្តនៃគោលនយោបាយអភិវឌ្ឍន៍វិស័យសង្គម ។

ប្រការ៤: លេខាធិការដ្ឋានមានសិទ្ធិអញ្ជើញជំនាញការបរទេសពាក់ព័ន្ធចូលរួមតាមការចាំបាច់ និងមានភារកិច្ចរៀបចំលិខិតអញ្ជើញប្រជុំគ្រប់សមាជិក នៃក្រុមដឹកនាំការងារបើកផ្តល់សាច់ប្រាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យសង្គម និងរៀបចំខ្លឹមសារ របៀបវារៈ កំណត់ហេតុ និងបញ្ជីវត្តមាននៃអង្គប្រជុំ (អាចធ្វើឡើងជាភាសាអង់គ្លេសផងដែរ) ជាពិសេសរបាយការណ៍សង្ខេប ស្តីពីស្ថានភាពបើកផ្តល់សាច់ប្រាក់ជូនក្រសួងស្ថាប័ននានា ដែលអនុវត្តកម្មវិធីសកម្មភាពអាទិភាព ជូនដៃគូអ្នកផ្តល់ជំនួយដែលពាក់ព័ន្ធនានា ។

ប្រការ៥: អគ្គលេខាធិការ អគ្គនាយក ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និង ឯកឧត្តម អស់លោកដូចមានចែងក្នុងប្រការ១ និង ប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០៣

ជ. ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ
យុវជន និងកីឡា

អ៊ឹម_សិទ្ធី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. ហុង_ស៊ុនហួត

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន

- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងក្រសួងសុខាភិបាល
- ដូចប្រការ ១ និងប្រការ ២
- ឯកសារ និង កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ២៦៥ MOC / M 2003

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០០៣

# ប្រកាស

## ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ២០០៣

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសុពលភាពនៃការបន្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខា កាលពី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១-** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រពន្ធអនុគ្រោះពាណិជ្ជកម្ម ( នាយកដ្ឋាន GSP ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី

១៧ ខែកញ្ញា ឆ្នាំ២០០៣ ត្រូវបានអញ្ជើញឱ្យមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ **Quota** ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

**ប្រការ២**- រោងចក្រនិមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណតិច ឬស្មើនឹងបរិមាណនៃ កូតា ដែលដាក់ ឱ្យដេញថ្លៃ តាមប្រភេទនិមួយៗនៃ **Quota** ដូចតទៅ :

| ប្រភេទ | បរិមាណដេញថ្លៃ ( DZ ) | ប្រភេទ | បរិមាណដេញថ្លៃ ( DZ ) |
|---|---|---|---|
| ៣៣៤/៦៣៤ | ១៨,៧៦៣ | ៣៥២/៦៥២ | ៤៣,៣១៧ |
| ៣៣៥/៦៣៥ | ៤៥០ | ៤៣៥ | ២០,២៧៦ |
| ៣៣៨/៣៣៩ | ២៥០ | ៤៣៨ | ៣៧,៧៩២ |
| ៣៤០/៦៤០ | ២៦០,៤១៣ | ៤៤៥/៤៤៦ | ៩៥,០៨៣ |
| ៣៤៥ | ២០,៣៤៧ | ៦៣៨/៦៣៩ | ១៩៨,១៣៥ |
| ៣៤៧/៣៤៨/៦៤៧/៦៤៨ | ៦៩៦ | ៦៤៥/៦៤៦ | ៩៥,៩៦៤ |

**ប្រការ៣**- ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ ពីធនាគារ **Certified Check** ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ប្រាក់ជូន គណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់ អប្បបរមាមិនគ្រប់ចំនួន ១០% នៃតម្លៃដេញថ្លៃសរុបនឹងចាត់ទុកថា ពាក្យសុំដេញថ្លៃ គ្មានប្រសិទ្ធភាព ។ ឧទាហរណ៍ រោងចក្រ **A**

ដេញថ្លៃ ចំនួន ២០ ០០០ ឡូ តំលៃ ៨ ដុល្លា/ឡូ = ១៦០,០០០ ដុល្លា

ទឹកប្រាក់កក់ ១០ % = ១៦,០០០ ដុល្លា

**ប្រការ៤**- ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម **Category** នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

**ប្រការ៥**- **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ៦**- តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ ២០ សេន ( ម្ភៃ ) នៃប្រាក់ដុល្លាសហរដ្ឋអាមេរិកលើ ថ្លៃឯកត្តាតាមប្រភេទ នីមួយៗ :

| | | | |
|---|---|---|---|
| Cat ៣៣៤/៦៣៤ | 3.00$/doz | Cat ៣៥២/៦៥២ | 0.60$/doz |
| Cat ៣៣៥/៦៣៥ | 3.00$/doz | Cat ៤៣៥ | 1.00$/doz |
| Cat ៣៣៨/៣៣៩ | 3.00$/doz | Cat ៤៣៨ | 1.00$/doz |
| Cat ៣៤០/៦៤០ | 0.80$/doz | Cat ៤៤៥/៤៤៦ | 0.50$/doz |
| Cat ៣៤៥ | 1.00$/doz | Cat ៦៣៨/៦៣៩ | 0.80$/doz |
| Cat ៣៤៧/៣៤៨/៦៤៧/៦៤៨ | 5.00$/doz | Cat ៦៤៥/៦៤៦ | 0.50$/doz |

**ប្រការ៧**- ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅអគារជាន់ទី២ លេខ ២០ B មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០ % នៃតំលៃដេញថ្លៃសរុប ដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨**- កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ចាប់ពីម៉ោង ៨:០០ ព្រឹក នៅទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគារលេខ ២០ អា ជាន់ទី២ មហាវិថីព្រះនរោត្តម ។

**ប្រការ ៩**- កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ វេលាម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០**- លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១**- អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបាន បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃ ដែលនៅសេសសល់ចំនួន ៩០ % រួចហើយ ។ កាលបរិច្ឆេទទូទាត់ចុងក្រោយ ត្រូវបានកំណត់ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៣ ។

**ប្រការ ១២**- អ្នកដេញថ្លៃដែលបានទទួលជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយកកូតារបស់ខ្លួនទៅប្រើប្រាស់ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតានោះ នឹងបន្តទុក

សំរាប់ដេញថ្លៃលើកក្រោយទៀត ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការ មិនអនុញ្ញាត ឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតា លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣**- អ្នកចូលរួមដេញថ្លៃ ដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

**ប្រការ ១៤**- Quota ដែលបានទទួល តាមរយៈការដេញថ្លៃនេះ ប្រើប្រាស់បានសំរាប់ឆ្នាំសារពើពន្ធ ២០០៣ តែប៉ុណ្ណោះ ។

**ប្រការ ១៥**- ការសំរេចចិត្តរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

**ប្រការ ១៦**- នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីស្តីទី

ស៊ុយ សែម

ចំលងជូន:

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

  " ដើម្បីជ្រាបជាពតិមាន "
- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚ ❖ ៙

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៤៧០ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **កញ្ជិល**

ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត ស្នើសុំរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាកញ្ជិល ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០២ និង លិខិតលេខ ៣៣២២ អយក.ត.បម របស់មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **តាកែវ** ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

**ស ំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **កញ្ជិល** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅភូមិ **កញ្ជិល** ឃុំ **កំពង់រាប** ស្រុក **ព្រៃកប្បាស** ខេត្ត **តាកែវ** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **កញ្ជិល** ត្រូវដឹកនាំដោយ នាយក១រូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ព្រៃកប្បាស** នាយកសាលាបឋមសិក្សា **កញ្ជិល** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **តាកែវ**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា.បស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ :៤៧១ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **ត្រពាំងកក់ក្នុង**

ជាឧបសម្ព័ន្ធរបស់ សាលាបឋមសិក្សា **កូនសត្វ**

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **ត្រពាំងកក់ក្នុង** ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត **កំពត** ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**សំរេច**

**ប្រការ១** : បើកសាលាបឋមសិក្សា**ត្រពាំងកក់ក្នុង** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **កូនសត្វ** ដែលមានទីតាំងស្ថិតនៅភូមិ **បុស្សញិញ** ឃុំ **កូនសត្វ** ស្រុក **កំពត** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ត្រពាំងកក់ក្នុង** ត្រូវមានប្រធានក្រុមម្នាក់ ទទួលខុសត្រូវ រួមជាមួយនាយកសាលាបឋមសិក្សា **កូនសត្វ** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **កំពត** នាយកសាលាបឋមសិក្សា **កូនសត្វ** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **ត្រពាំងកក់ក្នុង** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពត**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៥៧៦ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្ដាច់សាលាឧបសម្ព័ន្ធប្រជុំអង្គ មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ០១.០៣.បឋជក.របស់នាយកសាលាបឋមសិក្សាជើងកើប ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជននិង កីឡា ខេត្ត កណ្តាល ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

### សំ រេ ច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **ប្រជុំអង្គ** ពីសាលាបឋមសិក្សា **ជើងកើប** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ដែលមានទីតាំងស្ថិតនៅ ឃុំ **ជើងកើប** ស្រុក **កណ្តាលស្ទឹង** ខេត្ត **កណ្តាល** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ប្រជុំអង្គ** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជននិង កីឡាស្រុក **កណ្តាលស្ទឹង** នាយកសាលាបឋមសិក្សា **ជើងកើប** នាយកសាលាបឋមសិក្សា **ប្រជុំអង្គ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កណ្តាល

**ដើម្បីជូនជ្រាបជាពត៌មាន**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ ទា .បស

ភ្នំពេញ , ថ្ងៃទី ១៥ ខែ ៨ ឆ្នាំ ២០០៣

ក.ប. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙៣ ❖ ៙៚

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ ៥៧៣ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **ភ្នំសន្ទុង**

ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត ស្នើសុំរបស់គណៈកម្មការសាងសង់សាលាបឋមសិក្សា ភ្នំសន្ទុង ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០២ និង លិខិតលេខ ២៣៦៥ អយក.ត.បម របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ចុះថ្ងៃទី២៥ ខែ មីនា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាពរបស់អភិបាលរងទី ២ ខេត្ត តាកែវ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

**ស ំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **ភ្នំសន្ទុង** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅភូមិ **ក្រោម** ឃុំ សន្ទុង ស្រុក **ទ្រាំង** ខេត្ត **តាកែវ** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ភ្នំសន្ទុង** ត្រូវដឹកនាំដោយ នាយក១រូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និង កីឡាស្រុក **ស្រុកទ្រាំង** នាយកសាលាបឋមសិក្សា **ភ្នំសន្ទុង** មានភារកិច្ច អនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **តាកែវ**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា .បស

ភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣ ❖ ៤៧

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៤៧៤ អយក.ប្រក**

# ប្រកាស

ស្តីពី ការបើកសាលាបឋមសិក្សា **ហ៊ុន សែន ធាទិតលើ**

ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត ស្នើសុំរបស់នាយកសាលាបឋមសិក្សា **ធាទិត** ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០០៣ និង ចំណារឯកភាពរបស់មន្ទីរ អប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**ស ំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **ហ៊ុន សែន ធាទិតលើ** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅភូមិ **តាម៉ែប** ឃុំ **ធាទិត** ស្រុក **ចន្ទ្រា** ខេត្ត **ស្វាយរៀង** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ហ៊ុន សែន ធាទិតលើ** ត្រូវដឹកនាំដោយ នាយក១រូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ចន្ទ្រា** នាយកសាលាបឋមសិក្សា **ហ៊ុន សែន ធាទិតលើ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៣

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ស្វាយរៀង**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា .បស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ ៨៧៥ អយក.ប្រក

# ប្រកាស

## ស្តីពី ការបើកសាលាបឋមសិក្សា ស្នើសាមគ្គី ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា មាស គង់

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតស្នើសុំរបស់សហគមន៍ប្រចាំភូមិស្រះសំបូរ និងភូមិអងទង ឃុំ ពង្រ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០២ និង ចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ធំ លេខ ១០៦០ អយក.កធ.រប. ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

### សំរេច

**ប្រការ១** : បើកសាលាបឋមសិក្សា **ស្នើសាមគ្គី** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **មាស គង់** ដែលមានទីតាំងស្ថិតនៅភូមិ **ស្រះសំបូរ** ឃុំ **ពង្រ** ស្រុក **បារាយណ៍** ខេត្ត **កំពង់ធំ** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ស្នើសាមគ្គី** ត្រូវមានប្រធានក្រុម១ នាក់ ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **មាស គង់** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **កំពង់ធំ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **បារាយណ៍** នាយកសាលាបឋមសិក្សា **មាស គង់** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **ស្នើសាមគ្គី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កំពង់ធំ

"ដើម្បីជូនជ្រាបជាពត៌មាន"

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា.បស

ភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ០៥ អយក.សរណន

# សារាចរណែនាំ
## ស្តីពី
## ការផ្តល់អាហារូបករណ៍ ( រៀនមិនបង់ថ្លៃ ) ចំពោះនិស្សិតអាទិភាព ក្នុងការចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ សំរាប់ឆ្នាំសិក្សា ២០០៣-២០០៤

***&***

**យោង** : -ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៥ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-ប្រកាសលេខ ៤៥០ អយក.ប្រក ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០០២ ស្តីពីបទបញ្ជាជ្រើសរើសនិស្សិតអោយចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

-ប្រកាសលេខ ៧៦ អយក.ប្រក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការកំនត់តំបន់ជួបការលំបាក

-ការសំរេចរបស់អង្គប្រជុំនៅក្រសួងអប់រំ យុវជន និង កីឡា នាថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៣

កន្លងមកការជ្រើសរើសនិស្សិតអោយទទួលអាហារូបករណ៍ចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ត្រូវបានបែងចែកកន្លែងមួយចំនួនសំរាប់និស្សិតដែលមានអាទិភាព ប៉ុន្តែការជ្រើសរើសនេះ ក្រសួងបានសង្កេតឃើញថា មានគ្រឹះស្ថានសិក្សាខ្លះអនុវត្តបានល្អ តែក៏មានគ្រឹះស្ថានសិក្សាខ្លះអនុវត្តនៅពុំទាន់បានល្អនៅឡើយ ។ ដើម្បីសំរួលដល់ការជ្រើសរើស និង ដើម្បីអោយមានការឯកភាពគ្នាពីគ្រឹះស្ថានសិក្សាមួយទៅគ្រឹះស្ថានសិក្សាមួយទៀត ចំពោះការផ្តល់អាហារូបករណ៍ដល់និស្សិតដែលមានអាទិភាព ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

១-និស្សិតអាទិភាពត្រូវបានកំនត់ជា៣ប្រភេទ :

ប្រភេទទី១ : និស្សិតក្រីក្រ

ប្រភេទទី២ : និស្សិតជនជាតិភាគតិច និងនិស្សិតរស់នៅក្នុងខេត្តក្រុងដាច់ស្រយាល វិតំបន់ជួបការលំបាក

ប្រភេទទី៣ : និស្សិតជានារីភេទ

២-ចំនួនភាគរយ នៃកន្លែងអាហារូបករណ៍សំរាប់និស្សិតអាទិភាព នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នីមួយៗមាន ៣០% នៃចំនួនកន្លែងអាហារូបករណ៍សរុប ដែលត្រូវបានបែងចែក

ដូចខាងក្រោម ៖

-និស្សិតក្រីក្រ ១០%

-និស្សិតជនជាតិភាគតិច និងនិស្សិតមកពីខេត្តក្រុងដាច់ស្រយាលរឺតំបន់ជួបការលំបាក១០%

-និស្សិតជានារីភេទ ១០%

៣-និស្សិតក្រីក្រត្រូវមានចំនុចសំគាល់ជាមូលដ្ឋាន ដូចខាងក្រោម ៖

-ឪពុក និង ម្តាយស្លាប់

-ឪពុក រឺ ម្តាយស្លាប់

-ឪពុក រឺ ម្តាយនៅរស់តែចូលនិវត្តន៍ រឺ ចាស់ជរា

-ឪពុក រឺ ម្តាយជាយោធិនរំសាយ រឺ ពិការ

-ឪពុក រឺ ម្តាយជាកម្មករ រឺ កសិករក្សេរកមួយថ្ងៃសំរាប់មួយថ្ងៃ

-មានបងប្អូនបង្កើតចាប់ពី ៥នាក់ឡើងដែលពុំមានការងារធ្វើ

-សព្វថ្ងៃស្នាក់នៅតាមវត្តអារាម រឺ មណ្ឌលកុមារកំព្រា រឺ ផ្ទះមិត្តភក្តិសាច់ញាតិ

-ក្រុមគ្រួសារមានដីធ្លីមិនលើសពី៣០ម៉ែត្រក្រឡា

-គ្មានកេរ្តិ៍មរតក

-មានមធ្យោបាយធ្វើដំណើរត្រឹមតែរទេះគោ រឺ កង់ រឺ ថ្មើរជើង

-ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារមានកំរិតទាបជាងមួយលានរៀល

-ពុំមានមិត្តភក្តិ , ញាតិ រឺ អ្នកណាមួយជួយផ្តល់ប្រាក់ក្នុងការរស់នៅ និង រៀនសូត្រ

៤-និស្សិតជាជនជាតិភាគតិច ៖ ជាជនជាតិដែលមានដើមកំណើតនៅខេត្ត-ក្រុង ដាច់ស្រយាល និង បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅទីនោះ

៥-និស្សិតមកពីតំបន់ដាច់ស្រយាល ៖ ជានិស្សិតដែលមានដើមកំនើតមកពីតំបន់ដាច់ស្រយាល រឺ តំបន់ជួបការលំបាក ហើយបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅទីនោះ

៦-ខេត្ត-ក្រុងដាច់ស្រយាល និង តំបន់ជួបការលំបាក ៖

ក- ខេត្ត-ក្រុងដាច់ស្រយាលរួមមាន ៖ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកោះកុង និង ក្រុងប៉ៃលិន

ខ-តំបន់ក្នុងខេត្ត-ក្រុងដែលកំនត់ជាតំបន់ជួបការលំបាក ៖

- <u>ខេត្តពោធិសាត់ មាន</u> ៖ ស្រុកភ្នំក្រវាញ ស្រុកវាលវែង

ស្រុកបាកាន ៖ ឃុំតាលោ

ស្រុកក្រគរ ៖ ឃុំឈើតុំ និង ឃុំស្វាយស

- <u>ខេត្តកំពង់ធំ មាន</u> : ស្រុកសណ្តាន់ ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ

ស្រុកកំពង់ស្វាយ : ឃុំផាត់សណ្តាយ ឃុំទីពេជ ឃុំដំរីស្លាប់ និង ឃុំជ័យ

ស្រុកស្ទោង : ឃុំពាមបាង ឃុំពពក ឃុំបន្ទាយស្ទោង ឃុំចំណារលើ និង ឃុំព្រះដំរី

ស្រុកបារាយណ៍ : ឃុំគគីធំ និង ឃុំបាក់ស្នា

ស្រុកសន្ទុក : ឃុំទីពោ និង ឃុំក្រយា

- <u>ខេត្តបាត់ដំបងមាន</u> : ស្រុករតនៈមណ្ឌល ស្រុកបវេល ស្រុកសំពៅលូន ស្រុកភ្នំព្រឹក្ស

ស្រុកកំរៀង ស្រុកគាស់ក្រឡ ស្រុកសំឡូត

ស្រុកឯកភ្នំ : ឃុំកោះជីវាំង និង ឃុំព្រៃចាស់

ស្រុកមោងឫស្សី : ឃុំព្រៃត្រឡាច

- <u>ខេត្តសៀមរាប មាន</u> : ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកវ៉ារិន ស្រុកអង្គជុំ ស្រុកអង្គរធំ

ស្រុកបន្ទាយមានជ័យ : ឃុំឃុនរាម ឃុំរំចេក ឃុំត្បែង និង ឃុំរន្ធតាអក

ស្រុកជីក្រែង : ឃុំអន្លង់សំណរ ឃុំខ្វាវ ឃុំគោកធ្លកលើ ឃុំពង្រលើ ឃុំពង្រក្រោម ឃុំឫស្សីលក ឃុំល្វែងឫស្សី ឃុំស្ពានត្នោត និង ឃុំសង្វើយ

ស្រុកក្រឡាញ់ : ឃុំរោងគោ ឃុំស្នួល ឃុំក្រូចគោ ឃុំសែនសុខ និង ឃុំសំបូរ

ស្រុកសូត្រនិគម : ឃុំពពេល ឃុំចាន់សរ ឃុំខ្នាពោធិ ឃុំតាយ៉ែតនិង ឃុំកំពង់ឃ្លាំង

ស្រុកពួក : ឃុំកែវពិណ ឃុំរើល ឃុំត្រីញ័រ ឃុំល្វា ឃុំយាង ឃុំក្តីរុន ឃុំពោធិទ្រាយ និង ឃុំដូនកែវ

ស្រុកសៀមរាប : ឃុំនគរធំ និង ឃុំចុងឃ្នៀស

ស្រុកប្រាសាទបាគង : ឃុំអំពិល ឃុំបាល័ង្គ និង ឃុំកំពង់ភ្លុក

- <u>ខេត្តកំពង់ចាម មាន</u> : ស្រុកតំបែរ

ស្រុកមេមត់ : ឃុំទ្រាក ឃុំរូង ឃុំចាន់មូល ឃុំជាំក្រវៀន ឃុំទន្លូង ឃុំជាំតាម៉ៅ ឃុំដាំ ឃុំត្រម៉ោង ឃុំមេមង ឃុំគគីរ ឃុំកំពាន់ ឃុំរំចេក និង ឃុំរូង

ស្រុកស្ទឹងត្រង់ : ឃុំអូរម្លូ ឃុំដងក្តារ ឃុំអារក្សត្នោត និង ឃុំ ខ្ពបតាងួន

ស្រុកចំការលើ : ឃុំតាប្រុក និង ឃុំចំការអណ្តូង

ស្រុកត្បូងឃ្មុំ : ឃុំថ្មពេជ្រ ឃុំគរ ឃុំល្បៀង និង ឃុំ រកាពប្រាំ

ស្រុកពញាក្រែក : ឃុំវាលម្លូ ឃុំកក់ និង ឃុំត្រពាំងផ្លុង

- ខេត្តបន្ទាយមានជ័យ មាន : ស្រុកម៉ាឡៃ ស្រុកថ្មពួក ស្រុកភ្នំស្រុក

ស្រុកព្រះនេត្រព្រះ : ឃុំរហាល ឃុំទឹកជោរ ឃុំប្រាសាទ ឃុំទានកាំ និង ឃុំភ្នំលៀប

ស្រុកស្វាយចេក : ឃុំផ្គាំ ឃុំតាផូ ឃុំស្វាយចេក ឃុំសារង្គ ឃុំស្លក្រាម ឃុំទ្រាល ឃុំតាបែន និង ឃុំរលួស

ស្រុកអូរជ្រៅ : ឃុំអូបីជាន់ ឃុំនិមិត្ត ឃុំសឹង្ហ ឃុំសំរោង និង ឃុំប៉ោយប៉ែត

ស្រុកសិរីសោភ័ណ : ឃុំបុសស្បូវ

ស្រុកមង្គលបូរី : ឃុំសំបួរ ឃុំគោកបល្ល័ង្គ ឃុំសឿ និង ឃុំចំណោម

- ខេត្តកំពង់ស្ពឺ មាន : ស្រុកថ្ពង់ ស្រុកឱរ៉ាល់

ស្រុកភ្នំស្រួច : ឃុំទាំងអស់នៅក្នុងស្រុកភ្នំស្រួច លើកលែងតែ ឃុំមហាសាំង

ស្រុកបរសេដ្ឋ : ឃុំកាត់ភ្លុក ឃុំភក្តី ឃុំកក់ និង ឃុំព្រះខែ

ស្រុកសំរោងទង : ឃុំទំព័រមាស និង ឃុំតាំងក្រូច

ស្រុកឧត្តុង្គ : ឃុំជម្ពូព្រឹក្ស

- ខេត្តក្រចេះ មាន :

ស្រុកស្នួល : ឃុំស្រែចារ និង ឃុំខ្សឹម

ស្រុកសំបូរ : ឃុំរលួស ឃុំស្រែជិះ ឃុំបឹងចារ ឃុំអូរគ្រៀង និង ឃុំក្បាលដំរី

ស្រុកឆ្លូង : ឃុំកំពង់ដំរី និង ឃុំដំរីផុង

- ខេត្តកំពត មាន : ស្រុកដងទុង ស្រុក ជុំគីរី

ស្រុកឈូក : ឃុំល្បើក ឃុំត្រពាំងឃ្លាំង និង ឃុំតាកែន

ស្រុកកំពត : ឃុំស្ទឹងកែវ និង ឃុំព្រៃថ្នង់

ស្រុកកំពង់ត្រាច: ឃុំឫស្សីស្រុកខាងកើត ឃុំបឹងសាលាខាងត្បូង ឃុំបឹងសាលាខាងជើង និង ឃុំព្រែកក្រើស

ស្រុកបន្ទាយមាស : ឃុំត្នោតចុងស្រង់ ឃុំព្រៃទន្លេ ឃុំបន្ទាយមាសខាងលិច ឃុំបន្ទាយមាសខាងកើត និង ឃុំស្ដេចគង់ខាងត្បូង

- ខេត្តតាកែវ មាន : ស្រុកបូរីជលសារ ស្រុកកោះអណ្តែត ស្រុកអង្គរបូរី

ស្រុកគីរីវង់ : ឃុំកំណប់ ឃុំសោម ឃុំតាអូ ឃុំកំពែង និង ឃុំគោកព្រេច

ស្រុកទ្រាំង : ឃុំអង្គកែវ ឃុំខ្វាវ ឃុំរនាម ឃុំធ្លក និង ឃុំសំបួរ

ស្រុកត្រាំកក់ : ឃុំអូរសារាយ និង ឃុំត្រពាំងក្រញូង

ស្រុកព្រៃកប្បាស : ឃុំកំពង់រាប

- <u>ខេត្តកណ្ដាល មាន</u> :

ស្រុកលើកដែក : ឃុំក្អមសំណ និង ឃុំសណ្ដារ

ស្រុកកោះធំ : ឃុំព្រែកជ្រៃ ឃុំសំពៅពូន និង ឃុំលើកដែក

ស្រុកស្អាង : ឃុំប្រាសាទ និង ឃុំព្រែកអំបិល

ស្រុកល្វាឯម : ឃុំបារុង ឃុំព្រៃឫស្សី ឃុំកោះកែវ និង ឃុំសំបួរ

ស្រុកមុខកំពូល : ឃុំសំបួរមាស និង ឃុំស្វាយអំពារ

ស្រុកខ្សាច់កណ្ដាល : ឃុំជ្រៃធំ និង ឃុំរកាជន្លឹង

ស្រុកពញាឮ : ឃុំកំពង់លួង ឃុំកោះចិន ឃុំកំពង់អុស និង ឃុំសំរោង

- <u>ខេត្តព្រៃវែង មាន</u> :

ស្រុកព្រះស្ដេច : ឃុំបន្ទាយចក្រី និង ឃុំព្រះស្ដេច

ស្រុកពាមជរ : ឃុំក្រាំងតាយ៉ង ឃុំកោះសំពៅ និង ឃុំកោះរការ

ស្រុកកំពង់ត្របែក : ឃុំពាមមន្ទា ឃុំជាងដែក និង ឃុំចាម

ស្រុកពារាំង : ឃុំមេសប្រចាន់

ស្រុកស៊ីធរកណ្ដាល : ឃុំព្នៅទីពីរ

- <u>ខេត្តកំពង់ឆ្នាំង មាន</u> : ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ស្រុកជលគីរី

ស្រុកកំពង់ត្រឡាច : ឃុំអំពិលទឹក

ស្រុកកំពង់លែង : ឃុំផ្លូវទឹក ឃុំប្រឡាយមាស ឃុំច្រនូក និង ឃុំសំរោងសែន

ស្រុករលាប្អៀរ : ឃុំប្រស្និប

ស្រុកបរិបូរណ៍ : ឃុំកំពង់ព្រះ ឃុំគគីរ ឃុំអញ្ចាញរូង ឃុំប្រពេចចង្វារ និង ឃុំត្រពាំងចាន់

- <u>ខេត្តស្វាយរៀង មាន</u> :

ស្រុកចន្ទ្រា : ឃុំសំរោង ឃុំទូលស្ដី និង ឃុំចន្ទ្រា

ស្រុកស្វាយទាប : ឃុំមនោរម្យ និង ឃុំព្រៃតាអ៊ី

ស្រុករមាសហែក : ឃុំគគីរ ឃុំត្រស់ ឃុំអណ្ដូងត្របែក និង ឃុំសម្បត្តិមានជ័យ

- <u>ក្រុងកែប មាន</u> : ខ័ណ្ឌកែប និង ខ័ណ្ឌដំណាក់ចង្អើរ

- <u>ក្រុងព្រះសីហនុ មាន</u> : ខ័ណ្ឌមិត្តភាព : សង្កាត់កោះរុង

ខ័ណ្ឌព្រៃនប់ : សង្កាត់ព្រៃនប់

៧-ការកំណត់អាទិភាពចំពោះខេត្តក្រុងដាច់ស្រយាល និង តំបន់ជួបការលំបាក :

អាទិភាពទី១ : ខេត្តក្រុងដាច់ស្រយាល ដូចមានក្នុងចំនុច " ៦.ក "

អាទិភាពទី២ : ភូមិ ឃុំ ស្រុកជួបការលំបាកនៃខេត្តមួយចំនួនដូចមានក្នុងចំនុច " ៦.ខ "

៨-វិធីជ្រើសរើស :

ក-គ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវកំណត់និទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប ក្នុងកំរិតមួយសមស្របដែលអាចទទួលយកបាន សំរាប់និស្សិតក្រីក្រ និស្សិតជនជាតិភាគតិច និង និស្សិតមកពីខេត្តក្រុងដាច់ស្រយាល រឺ តំបន់ជួបការលំបាក ។

ខ-សំរាប់និស្សិតក្រីក្រ : ត្រូវផ្អែកលើនិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប ដែលបានកំណត់ដូច ក្នុងចំនុច៨.ក និង គួបផ្សំជាមួយចំនុចសំគាល់ អំពីភាពក្រីក្រដែលមានក្នុងចំនុច ៣ ។ និស្សិតណាដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេ ហើយមានចំនុចសំគាល់អំពីភាពក្រីក្រច្រើនជាងគេ ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងគេក្នុងការទទួលអាហារូបករណ៍ ។

គ-សំរាប់និស្សិតជនជាតិភាគតិច និង និស្សិតមកពីខេត្ត-ក្រុងដាច់ស្រយាល រឺ តំបន់ជួប ការលំបាក : ត្រូវផ្អែកលើនិទ្ទេសតាមមុខវិជ្ជា និងនិទ្ទេសសរុបដែលបានកំណត់ដូចក្នុងចំនុច ៨.ក និង គួបផ្សំជាមួយចំនុចអាទិភាពនៅតំបន់ដាច់ស្រយាលតំបន់ជួបការលំបាកអាចគួបផ្សំបន្ថែមនូវចំនុចក្រីក្រ ។ និស្សិតណា ដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេ ហើយមានស្ថានភាពភូមិសាស្ត្ររស់នៅ និងក្រីក្រលំបាកជាងគេ ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងគេ ក្នុងការទទួលអាហារូបករណ៍ ។

ឃ-សំរាប់និស្សិតជានារីភេទ : និស្សិតនារីដែលបានកំនត់ថាធ្លាក់ក្នុងពេលជ្រើសរើសផ្អែកនិស្សិតទូទៅនៅក្នុងមុខជំនាញណាមួយ ហើយដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេក្នុងចំនួនកំនត់យកផ្អែកអាទិភាពនារី លើមុខជំនាញនោះ ត្រូវបានចាត់ទុកថា បានជាប់ទទួលអាហារូបករណ៍ផ្អែកអាទិភាពនារី ក្នុងមុខជំនាញនោះ ។

ង-ក្នុងករណីជ្រើសរើស នៅក្នុងប្រភេទអាទិភាពណាមួយពុំបានគ្រប់ចំនួន ១០% ចំនួនដែលនៅសល់ត្រូវ បន្ថែមទៅក្នុងអាទិភាពផ្សេងៗទៀត តែចំនួនភាគរយសរុប នៃកន្លែងអាហារូបករណ៍សំរាប់និស្សិត អាទិភាពមិនអោយលើសពី ៣០% នៃចំនួនកន្លែងអាហារូបរកណ៍សរុបឡើយ ។

ច-គណៈកម្មការជ្រើសរើសត្រូវធ្វើការថ្លឹងថ្លែង និង សំរេចអោយបានត្រឹមត្រូវដោយផ្អែកលើសំណុំឯកសាររបស់បេក្ខជនដែលមានការបញ្ជាក់ពីសមត្ថកិច្ចរដ្ឋអំណាច ។ សំណុំឯកសាររបស់បេក្ខជនដែលគ្មានការបញ្ជាក់ត្រឹមត្រូវពីសមត្ថកិច្ច រដ្ឋអំណាចត្រូវចាត់ទុកថា គ្មានបានការ ។

បន្ទាប់ពីបានទទួលសារាចរណែនាំនេះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលធ្វើការជ្រើសរើសនិស្សិតអាទិភាពអោយទទួលអាហារូបករណ៍ចូលរៀនថ្នាក់ឆ្នាំទី១ ត្រូវអនុវត្តដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**<u>កន្លែងទទួល</u> :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ.ឧបរ - អគ.រហ

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា

" *<u>ដើម្បីជ្រាបជាពត៌មាន</u>*"

-គ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ " *<u>ដើម្បីអនុវត្ត</u>* "

-កាលប្បវត្តិ

-ឯកសារ : ន.ឧស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

D:\B Chanda\Sara Da Ch.doc

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៤៨១ សរណន.កសក

## សារាចរណែនាំ

## ស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និងធ្វើអាជីវកម្មដើមត្នោត

~~~~~~

ប្រជាជនខ្មែរយើងទាំងអស់គ្នាមានមោទនភាព និងកិត្យានុភាពយ៉ាងក្រៃលែង ដោយសារបុព្វបុរសយើងជាច្រើនជំនាន់កន្លងមក បានខិតខំតស៊ូព្យាយាមដាំដុះ ថែរក្សា និងការពាររហូតបានបន្សល់ទុកជាស្នាដៃកេរ្តិ៍តំណែលដ៏មានតម្លៃខាងសេដ្ឋកិច្ច វប្បធម៌ និងប្រវត្តិសាស្ត្រ ឱ្យដល់ជំនាន់យើងសព្វថ្ងៃនេះ នូវប្រភេទរុក្ខជាតិដើមត្នោតយ៉ាងច្រើនសន្ធឹកសន្ធាប់នៅពាសពេញក្នុងផ្ទៃប្រទេស ។ នាពេលបច្ចុប្បន្ននេះទៀតសោត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានសង្កេតឃើញបងប្អូនកសិករយើងនៅតាមខេត្ត-ក្រុងជាច្រើន ពិសេសបងប្អូនប្រជាកសិកដែលនៅជិតដងផ្លូវដឹកជញ្ជូនសំខាន់ៗ បាន និងកំពុងនាំគ្នាកាប់ដើមត្នោតយ៉ាងអនាធិបតេយ្យដើម្បីលក់ឱ្យឈ្មួញប្រមូលផ្តុំទិញ និង ដឹកជញ្ជូនយកទៅលក់បន្តនៅខេត្តព្រៃវែង ស្វាយរៀង និងតាកែវ ដែលខ្វះខាតឈើសាងសង់ ហើយទន្ទឹមនោះ ក៏នៅមានឈើត្នោតទាំងនោះមួយចំនួនធំបំផុតផងដែរ ដែលបាន និងកំពុងនាំចេញ ទៅលក់ជាបន្តទៀតនៅក្រៅប្រទេស ។ ករណីនេះកើតឡើងដោយសារមានឈ្មួញកណ្តាលជាអ្នកបំផុសឱ្យកាប់ និងដើរប្រមូលទិញធ្វើអាជីវកម្ម ដែលធ្វើឱ្យសកម្មភាពនេះកាន់តែរីកសាយភាយកាន់តែរីករាលដាលកាន់តែច្រើនឡើងៗពីតំបន់មួយទៅដល់តំបន់មួយទៀតជាបន្តបន្ទាប់ ។ ទង្វើខាងលើនេះ គឺដោយសារប្រជាកសិករខ្លះគិតថា ដើមត្នោតដុះក្នុងបរិវេណដីកម្មសិទ្ធិរបស់គាត់ គាត់មានសិទ្ធិប្រើប្រាស់ និងលក់ដូរទៅតាមតម្រូវការរបស់គាត់ដោយភ្លេចគិតដល់សារៈប្រយោជន៍ដ៏ច្រើនលើសលុបនៃដើមត្នោតដែលមានលើសពីរុក្ខជាតិផ្សេងៗ និង ជារុក្ខជាតិដែលតំណាងឱ្យប្រទេសជាតិកម្ពុជា និងតំណាងឱ្យព្រលឹងជាតិខ្មែរដូចដែលមានចម្លាក់នៅលើផ្ទាំងជញ្ជាំងអង្គរវត្តជាសក្ខីភាពស្រាប់ ។ នៅលើពិភពលោកជាពិសេសនៅភូមិភាគអាស៊ី គឺមានតែប្រទេសកម្ពុជាយើងទេដែលមានដើមត្នោតច្រើនជាងគេ ។

ដោយពិនិត្យឃើញពីផលប្រយោជន៍ខាងសេដ្ឋកិច្ច ប្រវត្តិសាស្ត្រ និងវប្បធម៌របស់ដើមត្នោតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមធ្វើការណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត-ក្រុង ដូចតទៅ :

១-ត្រូវធ្វើការផ្សព្វផ្សាយពីផលវិបាកនៃការបាត់បង់ដើមត្នោត ពីផលប្រយោជន៍ និងតម្លៃនៃដើមត្នោតជូនប្រជាពលរដ្ឋ ឱ្យបានយល់ជ្រួតជ្រាប ។

២-ត្រូវណែនាំបំផុសឱ្យប្រជាពលរដ្ឋបានយល់ដឹង និងចេះប្រើប្រាស់ដើមត្នោតឱ្យអស់លទ្ធភាព ហើយក្នុងករណីចាំបាច់យកមកប្រើប្រាស់ជាគ្រឿងសំណង់គ្រួសារផ្ទាល់នោះ គប្បីកាប់តែដើមត្នោតណាដែលមានអាយុច្រើនឬដែលលែងផ្តល់

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B-V D Phnom-Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320
~~~~~~

D:\B Chanda\Sara Da Ch.doc

ផល ហើយជៀសវាងការកាប់ដើមត្នោតនៅក្មេងកំពុងផ្តល់ផល ។ ក្នុងករណីនេះ ក៏ត្រូវណែនាំឱ្យដាំជួសវិញឱ្យបានយ៉ាងតិចទ្វេរដងដែរ ។

៣-ត្រូវជំរុញឱ្យប្រជាពលរដ្ឋខិតខំថែរក្សា និងដាំដើមត្នោតនៅលើដីទួលឬដីទំនេរ ដើម្បីជំនួសដើមត្នោតដែលបានកាប់យកមកប្រើប្រាស់ផង និងដើម្បីធានាទៅអនាគតយូរអង្វែងសំរាប់ប្រទេសកម្ពុជាយើងឱ្យនៅតែមានដុះដើមត្នោតដែលជាតំណាងអត្តសញ្ញាណជាតិយើងនេះដ៏ច្រើន និងពាសពេញគ្រប់ខេត្ត-ក្រុងទៀតផង ។

៤-ត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ចុះស្រង់ស្ថិតិដើមត្នោតរបស់ប្រជាកសិករនៅគ្រប់ភូមិ ឃុំ និងអប់រំណែនាំ និងហាមឃាត់ការកាប់ដើមត្នោត ដើម្បីធ្វើអាជីវកម្មលក់ដូរចេញទៅកាន់ខេត្តផ្សេងៗ ។

៥- ត្រូវសហការជាមួយសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ដើម្បីត្រួតពិនិត្យនិងហាមឃាត់ឱ្យបាននូវការនាំចេញឈើត្នោតទៅក្រៅប្រទេស ។

៦-មន្ត្រីនាយកដ្ឋានរុក្ខា-ប្រមាញ់ ដែលមានបេសកកម្មចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើទូទាំងប្រទេស ត្រូវចូលរួមអនុវត្តជាបន្ថែមឱ្យបានតឹងរឹងបំផុតក្នុងដែនសមត្ថកិច្ចរបស់ខ្លួននូវការងារត្រួតពិនិត្យជាប្រចាំ ត្រូវហាមឃាត់ និងទប់ស្កាត់រាល់ការដឹកជញ្ជូនឈើត្នោត និងដើមត្នោតចេញពីខេត្តមួយឆ្ពោះទៅកាន់ខេត្តក្រៅផ្សេងទៀត ដោយសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរពាក់ព័ន្ធ ។

ក្រោយពីទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវខ្លឹមសារសារាចរណែនាំនេះ ។ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់នឹងចាត់វិធានការទប់ស្កាត់នូវការកាប់ និងការធ្វើអាជីវកម្មដឹកជញ្ជូនដើមត្នោតដោយអនាធិបតេយ្យ ដើម្បីរួមចំណែកក្នុងការការពាររុក្ខជាតិតំណាងឱ្យប្រទេសជាតិបានគង់វង្ស ជាមិនខាន ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

ចាន់ សារុន